# សេចក្តីប្រកាស

## ដៃគូអភិវឌ្ឍន៍អំពាវនាវសុំឱ្យបញ្ឈប់ការបណ្តេញប្រជាជនកម្ពុជាក្រីក្រនៅទីក្រុង

**ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០០៩** — ដៃគូអភិវឌ្ឍន៍ អំពាវនាវដល់រដ្ឋាភិបាលកម្ពុជា ឱ្យបញ្ឈប់ការបណ្តេញចេញដោយកំលាំង ចំពោះប្រជាជនដែលតាំងទីលំនៅនៅតំបន់មានជំលោះនៅរាជធានីភ្នំពេញ និង នៅកន្លែងផ្សេងៗទៀតនៅក្នុងប្រទេស រហូតដល់ពេលមានយន្តការសមស្រប និងតម្លាភាពសំរាប់ដោះស្រាយជំលោះត្រូវបានរៀបចំឡើង និងគោលនយោបាយស្តីអំពីការផ្លាស់ប្តូរលំនៅដ្ឋានដ៏ទូលំទូលាយមួយត្រូវបានរៀបចំ ។

ដៃគូអភិវឌ្ឍន៍មើលឃើញថា បញ្ហាដីធ្លីកំពុងតែមានការប្រឈម ដល់ការអភិវឌ្ឍន៍នៅក្នុងប្រទេស ហើយទទួចសុំឱ្យរដ្ឋាភិបាលអនុម័តប្រព័ន្ធដែលសមស្រប និងមានតល្លាភាព សំរាប់ធ្វើកម្មសិទ្ធិដីធ្លី ដោយរួមទាំងអ្នកនៅតំបន់ទីក្រុងដែលទទួលស្គាល់ និងការពារដោយសិទ្ធិស្មើភាពគ្នាចំពោះប្រជាពលរដ្ឋទាំងអស់ ។ ដៃគូអភិវឌ្ឍន៏ត្រៀមជាស្រេចហើយដើម្បីគាំទ្រក្នុងការបង្កើតសេចក្តីណែនាំគោលនយោបាយជាតិ ដែលវានឹងធានាថាការបណ្តេញ និងការផ្លាស់ប្តូរលំនៅដ្ឋានធ្វើឡើងស្របទៅនឹងនិតិវិធីច្បាប់ និងផ្តល់សំណងសមស្របដល់អ្នកដែលរងការប៉ះពាល់ ។

ធនាគារពិភពលោក និងដៃគូអភិវឌ្ឍន៍មួយចំនួនបានធ្វើការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល លើសុវត្ថភាពកម្មសិទ្ធិដីធ្លីនៅកម្ពុជា។ រដ្ឋាភិបាលទទួលបានការលើកសរសើរចំពោះការផ្តល់ជូនប័ណ្ណកម្មសិទ្ធិ ជាង ១ លាន សន្លឹក ដល់ប្រជាជនព្រោះវាផ្តល់ឱកាសសំរាប់ការលើកកំពស់កំណើន និងការកាត់បន្ថយភាពក្រីក្រ ។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងបរិយាកាសដែលតំលៃដីនៅទីក្រុងកើនឡើងយ៉ាងខ្លាំងនៅកម្ពុជា និង ការទិញ-លក់ដី ដែលធ្វើឱ្យអ្នករស់នៅទីក្រុងទទួលរងការគំរាមកំហែងនៃការផ្លាស់ប្តូរលំនៅដ្ឋាន ដើម្បីយកទីនោះ សំរាប់ការអភិវឌ្ឍទ្រព្យសម្បត្តិដែលមានតំលៃខ្ពស់ ។ ប្រការនេះបានបង្កើតឱ្យមានបញ្ហាដ៏ធំមួយនៅភ្នំពេញ និងនៅទីក្រុងនានាដែលមានកំណើនសេដ្ឋកិច្ចលឿននៅកម្ពុជា ហើយវាបានបង្កើតជាបញ្ហាមិនប្រាកដប្រជាមួយ និងបានដាក់ការរស់នៅរបស់ប្រជាជនក្រីក្ររាប់ពាន់នាក់ដែលរស់នៅក្នុងតំបន់ជំលោះ ស្ថិតក្នុងស្ថានភាពហានិភ័យ។ នេះគឺជាលទ្ធផលនៃគោលនយោបាយ និងការអនុវត្តដែលមិនសមស្របទៅនឹងការអនុវត្តល្អបែបអន្តរជាតិក្នុងការដោះស្រាយជំលោះ និង ការផ្លាស់ប្តូរលំនៅដ្ឋាន ហើយមិនបានប្រើប្រាស់ឱ្យមានប្រសិទ្ធិភាពចំពោះនីតិវិធីនានា និងស្ថាប័ននានា ដែលមាននៅក្នុងច្បាប់របស់កម្ពុជា។

បទពិសោធន៍អន្តរជាតិ បានបង្ហាញថា សុវត្ថភាពកម្មសិទ្ធិដីធ្លី គឺមានសារៈសំខាន់ណាស់ក្នុង ការធានាឱ្យមានកំណើន សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ហើយការអនុវត្តចំពោះដំណើរការផ្លាស់ប្តូរលំនៅដ្ឋាន ដ៏ប្រសើរ គឺជាគន្លឹះដើម្បី ធ្វើឱ្យមានការកាន់កាប់ដីធ្លី និងការផ្តល់ដីធ្លីជាប្រព័ន្ធប្រកដដោយប្រសិទ្ធិភាព ហើយវានឹងការពារសិទ្ធិរបស់ប្រជាជន ទាំងអស់។

ដៃគូអភិវឌ្ឍន៍ សូមអះអាងនូវការប្តេជ្ញាចិត្តជាថ្មីម្តងទៀត ធ្វើការជាមួយរដ្ឋាភិបាល ដើម្បីជួយដោះស្រាយបញ្ហាដីធ្លី ក្នុងន័យប្រកបដោយយុត្តិធម៌ និងសមធម៌ ហើយធានាថាសិទ្ធិរបស់ប្រជាជនក្រីក្រត្រូវបានលើកកំពស់ និងការពារ។

**ចុះហត្ថលេខាដោយ:**

ស្ថានទូតអូស្ត្រាលី

ស្ថានទូតប៊ុលហ្គារី

ស្ថានទូតដាណឺម៉ាក- ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក

ស្ថានទូតអាល្លឺម៉ង់

ស្ថានទូតចក្រភពអង់គ្លេស (ជាតំណាងឱ្យប្រធានសហភាពអឺរ៉ុប)

ស្ថានទូតអាមេរិក

ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត

ធនាគារអភិវឌ្ឍន៍អាស៊ី

សហគមន៍អឺរ៉ុប

អង្គការសហប្រជាជាតិ

ធនាគារពិភពលោក

ទំនាក់ទំនង: ធនាគារពិភពលោក

លោក ប៊ូ សារឿន មន្ត្រីទំនាក់ទំនងព័ត៌មាន ទូរស័ព្ទ (៨៥៥ ២៣) ២១៧ ៣០១ អ៊ីម៉ែល: sbou@worldbank.org